Documentation Center of Cambodia [DC-Cam]
MAPPING THE KILLING FIELDS OF CAMBODIA, 1997

# SITE FORM

Date : 20/8/98 ID no: 010302 Team : ____
Latitude : N 134702.22 Longitude : E 1031852
File # R 082004 A Time 11:20 AM Location: ____

Site Name : La-ang Trapeang Thma [Kh] : ឡានត្រពាំងថ្ម khet Banteay Mean Chey
srok : Phnom Srok khum : Poy Cha phum Trapeang Thma Kandal

| 1. PRISON | | (2.) Burial site | | 3. Memorial | |
|---|---|---|---|---|---|
| Interrogation Ctr. | | Pit | | Wat | |
| Previous Prison | | Kiln | | Stupa | |
| Purpose Built | | Rice paddy | | Brick/tile | |
| School | | River/lake | ✓ | Wooden | |
| Wat | | Well | | Other | |
| House | | Execution | | | |
| Other | | Other | | | |

ACCESSIBILITY DESCRIPTION IN MOST DETAIL AS POSSIBLE:
The lake is located about 6 km west of the district office. We travelled across Poy Snuol village (3 km east of the lake)

WITNESS Name Chhum Ruom Age 50 Sex M Address
phum Srah Chik khum Srah Chik srok Phnom Srok
khet Banteay Mean Chey Identity ____
Estmated number of victim Thousands Pits A few pits (?) Other ____
[according to the witness ___ Report ___ Other ____]
Photos : ____ Roll Number : ____ Shots number ____
Documents: ____

Interview Recorded in tape

Comments: ____

Documentation Center of Cambodia [DC-Cam]
MAPPING THE KILLING FIELDS OF CAMBODIA, 1997

# SITE FORM

Date : 20/8/98 ID no: 010303 Team :
Latitude : N 13444597 Longitude : E 103194307
File # R 082005 A Time 12:30 PM Location:

Site Name : Prey Kok Trach [Kh] : ព្រៃគោកត្រាច khet Banteay Mean Chey
srok : Phnom Srok khum : Kok Trach phum : Kok Trach

| 1. PRISON | | (2.) Burial site | | 3. Memorial | |
|---|---|---|---|---|---|
| Interrogation Ctr. | | Pit | | Wat | |
| Previous Prison | | Kiln | | Stupa | |
| Purpose Built | | Rice paddy | ✓ | Brick/tile | |
| School | | River/lake | | Wooden | |
| Wat | | Well | | Other | |
| House | | Execution | | | |
| Other | | Other | | | |

ACCESSIBILITY DESCRIPTION IN MOST DETAIL AS POSSIBLE:
Prey Kok Trach is about 1500 m away from Phnom Srok district office.

WITNESS: Name Chhum Ruom Age 50 Sex M Address
phum Srah Chik khum Srah Chik srok Phnom Srok
khet Banteay Mean Chey Identity
Estmated number of victim Hundreds Pits ~~[illegible]~~ No pit (corpes scattered around) Other
[according to the witness Report Other ]
Photos : Roll Number : Shots number
Documents:

Interview : Recorded in tape

Comments:

Documentation Center of Cambodia [DC-Cam]
MAPPING THE KILLING FIELDS OF CAMBODIA, 1997

# SITE FORM

Date : 20/8/98 ID no: 010301 Team : ____
Latitude : N 13443203 Longitude : E 103200767
File # R 082003A Time 10:20 AM Location: ____
Site Name ~~Sala Srok Phnom Srok~~ Region security office [Kh] : ____ khet Banteay Mean Chey
srok : Phnom Srok khum : Srah Chik phum : Srah Chik

feature to be added

| 1. PRISON | | 2. Burial site | | 3. Memorial | |
|---|---|---|---|---|---|
| Interrogation Ctr. | | Pit | | Wat | |
| Previous Prison | ✓ | Kiln | | Stupa | |
| Purpose Built | | Rice paddy | | Brick/tile | |
| School | | River/lake | | Wooden | |
| Wat | | Well | | Other | |
| House | | Execution | | | |
| Other | | Other | | | |

ACCESSIBILITY DESCRIPTION IN MOST DETAIL AS POSSIBLE:
We departed from Banteay Mean Chey provincial town on National Road № 6. When we reached an intersection in Prey Moan village, we turned left and went 16 km further. Then we reached the district office.

WITNESS Name Chhum Ruom Age 50 Sex M Address
phum Kandal Khang Lech khum Srah Chik srok Phnom Srok
khet ____ Identity ____

Estmated number of victim Hundreds Pits 1 mass grave Other ____
[according to the witness ____ Report ____ Other ____]
Photos : ____ Roll Number : ____ Shots number ____
Documents: ____

Interview Recorded in tape

Comments: ____

Documentation Center of Cambodia [DC-Cam]
MAPPING THE KILLING FIELDS OF CAMBODIA, 1997

# SITE FORM

Date : 20/8/98 ID no: 010304 Team : ____
Latitude : N 13443815 Longitude : E 10320 7537
File # R 082005 B Time 12:45 PM Location: ____

Site Name : Wat Kandal [Kh] : ____ khet Banteay Mean Chey
srok : Phnom Srok khum : Srah Chik phum : Srah Chhouk Kandal

| 1. PRISON | | 2. Burial site | | (3.) Memorial | |
|---|---|---|---|---|---|
| Interrogation Ctr. | ____ | Pit | ____ | Wat | ✓ |
| Previous Prison | ____ | Kiln | ____ | Stupa | ____ |
| Purpose Built | ____ | Rice paddy | ____ | Brick/tile | ____ |
| School | ____ | River/lake | ____ | Wooden | ____ |
| Wat | ____ | Well | ____ | Other | ____ |
| House | ____ | Execution | ____ | | ____ |
| Other | ____ | Other | ____ | | ____ |

ACCESSIBILITY DESCRIPTION IN MOST DETAIL AS POSSIBLE:

WITNESS: Name Chhum Ruom Age 50 Sex M Address
phum Srah Chik khum Srah Chik srok Phnom Srok
khet Banteay Mean Chey Identity ____

Estmated number of victim ~~Hundreds~~ Pits ~~(?)~~ Other ____
[according to the witness ____ Report ____ Other ____]
Photos : ____ Roll Number : ____ Shots number ____
Documents: ____

Interview : Recorded in tape

Comments: ____

Documentation Center of Cambodia [DC-Cam]
MAPPING THE KILLING FIELDS OF CAMBODIA, 1997

data deleted as already mapped 1997

# SITE FORM

Date : 19/8/98 ID no: 010601 Team : ____
Latitude : N 13351011 Longitude : E 102574281
File # R·081903 A Time 11:00 AM Location: ____

Site Name : Wat Sopheak Mungkul [Kh] : វត្តសុភមង្គល khet Banteay Mean Chey
srok Serey Sophorn khum : O Ambel ? phum : O Ambel ?

1. PRISON
   - Interrogation Ctr. ____
   - Previous Prison ____
   - Purpose Built ____
   - School ____
   - Wat ____
   - House ____
   - Other ____
2. Burial site
   - Pit ____
   - Kiln ____
   - Rice paddy ____
   - River/lake ____
   - Well ____
   - Execution ____
   - Other ____
3. (circled) Memorial
   - Wat ✓
   - Stupa ____
   - Brick/tile ____
   - Wooden ____
   - Other ____

ACCESSIBILITY DESCRIPTION IN MOST DETAIL AS POSSIBLE:
The memorial site is located to the west of Salarien Ahnakoth, about 1 km from the provincial office.

WITNESS Name Sien Nhien Age 69 Sex M Address
phum O Ambel khum O Ambel srok Serey Sophorn
khet Banteay Mean Chey Identity ____

Estmated number of victim ~~[illegible]~~ Pits ~~(2)~~ Other ____
[according to the witness ____ Report ____ Other ____]
Photos ____ Roll Number : ____ Shots number ____
Documents: ____

Interview Recorded in tape

Comments: ____

Documentation Center of Cambodia [DC-Cam]
MAPPING THE KILLING FIELDS OF CAMBODIA, 1997

# SITE FORM

Date : 19/8/98 ID no: 010602 Team :
Latitude : N 13352846 Longitude : E 102572895
File # R081905A Time 12:55 PM Location:

Site Name : Chamkar Khnao [Kh] : khet Banteay Mean Chey
srok Serey Sophorn khum : O Ambel phum O Ambel

data deleted as already mapped 1997

P to be added

| 1. PRISON | | (2.) Burial site | | 3. Memorial | |
|---|---|---|---|---|---|
| Interrogation Ctr. | | Pit | ✓ | Wat | |
| Previous Prison | | Kiln | | Stupa | |
| Purpose Built | | Rice paddy | | Brick/tile | |
| School | | River/lake | | Wooden | |
| Wat | | Well | | Other | |
| House | | Execution | | | |
| Other | | Other | | | |

ACCESSIBILITY DESCRIPTION IN MOST DETAIL AS POSSIBLE:
Chamkar Khnao is located about 2 km south of the provincial office, and about 200m west of Wat Kiri Chum Chamkar Khnao.

WITNESS Name Saom Lang Age 63 Sex M Address
phum O Ambel khum O Ambel srok Serey Sophorn
khet Banteay Mean Chey Identity

Estmated number of victim more than 5000 Pits 5 Other
[according to the witness Report Other ]
Photos : Roll Number : Shots number
Documents:

Interview Recorded in tape

Comments:

Documentation Center of Cambodia [DC-Cam]
MAPPING THE KILLING FIELDS OF CAMBODIA, 1997

# SITE DATA FORM

**Province of:** Banteay Meanchey **Team :** DC-Cam **Date :** 19/8/-20/8/98

| ID CODE | SITE NAME | TYPE | srok | FILE NO. | LATITUDE N | LONGITUDE E |
|---|---|---|---|---|---|---|
| 010301 | Sala Srok Phnom Srok | P | Phnom Srok | R082003A | 13°44' 3203" | 103°20' 0767" |
| 010302 | La-ang Trapeang Thma | B | —"— | R082004A | 13°44' 0222" | 103°18' 1852" |
| 010303 | Prey Kok Trach | B | —"— | R082005A | 13°44' 4597" | 103°19' 4307" |
| 010304 | Wat Kandal | M | —"— | R082005B | 13°44' 3815" | 103°20' 7537" |
| 010601 | Wat Sopheak Mungkul | B | Serey Sophorn | R081903A | 13°35' 1011" | 102°57' 4281" |
| 010602 | Chamkar Khnao | B → P | Serey Sophorn | R081905A | 13°35' 2846" | 102°57' 2895" |
| | | P | to be added | | | |
| | | | | | | |
| | | | | | | |
| | | | | | | |

} already mapped 1997

មជ្ឈមណ្ឌលឯកសារកម្ពុជា

# របាយការណ៍
## ស្តីអំពីការចុះសិក្សាស្រាវជ្រាវឯកសារទាក់ទងអំពើឧក្រិដ្ឋកម្មរបស់
## បន ប៉ុល ពត នៅខេត្តបន្ទាយមានជ័យ

កាលពីថ្ងៃទី២៨ ខែឧសភា ឆ្នាំ១៩៩៧ មជ្ឈមណ្ឌលឯកសារកម្ពុជា សហការជាមួយនឹងបណ្ណសារដ្ឋានតំកល់ឯកសារ បានចាត់តាំងសហការី២នាក់ គឺលោក **ស៊ិន ឃិន** និងលោក **ហាក់ សុផល** ចុះទៅទំនាក់ទំនងសិក្សាស្រាវជ្រាវឯកសារទាក់ទងអំពើឧក្រិដ្ឋកម្មរបស់បន **ប៉ុល ពត** នៅស្រុកសេរីសោភ័ណ្ឌ ស្រុកមង្គលបូរី និងស្រុកព្រះនេត្រព្រះ ជាលើកទី១ ។

ក្រុមស្រាវជ្រាវឯកសារបានចេញពីទីក្រុងភ្នំពេញនៅវេលាម៉ោង៧ព្រឹក ឆ្ពោះទៅកាន់ខេត្តបន្ទាយមានជ័យ កាត់ខេត្តបាត់ដំបង តាមផ្លូវជាតិលេខ៥ ចម្ងាយផ្លូវ៣៩២គីឡូម៉ែត្រ ទៅដល់ទីរួមខេត្តបន្ទាយមានជ័យ ។

នៅវេលាម៉ោង ៩:៣០នាទី ថ្ងៃទី២៩។៤។៩៧ យើងបានដល់សាលាខេត្ត ជួបអភិបាលខេត្តស្តីទីលោក **គាត់ សុហ៊ុន** ដើម្បីការអនុញ្ញាតចុះធ្វើការក្នុងខេត្ត និងបណ្តាស្រុក ៣ ព្រមទាំងមន្ទីរវប្បធម៌ ខេត្ត ស្នងការនគរបាលខេត្តបន្ទាយមានជ័យ ។

### លក្ខណៈភូមិសាស្ត្រ

- **ព្រំប្រទល់របស់ខេត្ត**
- ខាងកើត: ជាប់ខេត្តបាត់ដំបង
- ខាងលិច: ប្រទេសថៃ
- ខាងជើង: ខេត្តសៀមរាបឧត្តរមានជ័យ
- ខាងត្បូង: ប្រទេសថៃ

## អំពីស្ថិតិជនរងគ្រោះស្លាប់ដោយអំពើឧក្រិដ្ឋកម្ម
## នៅខេត្តបន្ទាយមានជ័យ និងខេត្តបាត់ដំបង

សរុប : ៤៧១.៧៦១ នាក់ ក្នុងនោះមាន :

- កសិករ : ២៧១.៥៤១ នាក់

- មន្ត្រីរដ្ឋការ កម្មករ : ៥៤.២៣០ នាក់
- ព្រះសង្ឃ : ១.៩២៥ អង្គ
- ជនជាតិ : ៩២.៥៧៣ នាក់
- ជនពិការ : ១៤.២១៩ នាក់

- ចំនួនប្រជាជនធ្វើញត្តិប្តឹង ៤២៩.៤៨០ នាក់

សូមបញ្ជាក់ថា តួលេខបូកបញ្ចូលទៅខេត្តបាត់ដំបងនេះ ព្រោះពីមុនបន្ទាយមានជ័យមិនទាន់ បង្កើតឡើងទេ គឺឋិតនៅចំណុះខេត្តបាត់ដំបង បណ្តាស្រុកចំណុះខេត្តបន្ទាយមានជ័យជាស្រុកចំណុះខេត្ត បាត់ដំបងទាំងអស់ ក្នុងពេលចុះស្រង់ស្ថិតិនេះ ។

ខេត្តនោះឋិតនៅទិសពាយ័ព្យ តំបន់៥ សម័យ **ប៉ុល ពត** ។

នៅវេលាម៉ោង១០:១០ យើងបានទៅទាក់ទងមន្ទីរវប្បធម៌ ខេត្ត ជួបលោក **ហ៊ីង ធីម** ប្រធានមន្ទីរ លោក **លី ស្រ៊ាង** ប្រធានការិយាល័យរដ្ឋបាលស្រុក និងលោក **ប្រាក់ សុផល** ប្រធានការិយាល័យវប្បធម៌ស្រុក មន្ត្រីទាំងនោះ បានរួមសហការចុះផ្ទាល់ជាមួយយើងនៅស្រុកសេរីសោភ័ណ ស្រុកមង្គលបូរី ។

បន្ទាប់មកទៀត យើងទៅទាក់ទងស្នងការនគរបាលខេត្ត មានប៉ូលីស ០៣នាក់ រួមការងារគឺ :

១- លោក **ធីម រត្តនៈ** អនុប្រធានក្រុមតម្រួតបទបញ្ជា

២- លោក **សួស ឫទ្ធី** បុគ្គលិក

៣- លោក **ធិល សន្តៈ** បុគ្គលិក

អស់លោកទាំង៣នាក់នេះ បានរួមដំណើរការពារក្រុមយើង ស្រុកទាំង៣ រហូតដល់ចប់ការងារ ។

នៅវេលាម៉ោង១១:០០ យើងបានធ្វើដំណើរទៅកាន់ស្រុកសេរីសោភ័ណ ចម្ងាយផ្លូវពីខេត្ត ២គមនៅទីនេះមិនបានជួបមន្ត្រីរបស់ស្រុកទេ ។ ប៉ុន្តែដោយមានមន្ត្រីវប្បធម៌ខេត្ត ២នាក់ កងការពារ ហើយយើងធ្វើដំណើរទៅមណ្ឌលឧក្រិដ្ឋកម្មតែម្តង ។

\+ **មណ្ឌលឧក្រិដ្ឋកម្ម** E 102º 57' 2689" N13º 35' 3087" ចំការខ្នុរ ភូមិអូរបិល ឃុំអូរបិល (វត្តចំការខ្នុរ) ។

ទីនោះមានសន្តិសុខ និងគុក និងកន្លែងសម្លាប់ របស់បន **ប៉ុល ពត** ។ នៅទីនោះចម្ងាយពីសាលាស្រុកសេរីសោភ័ណ ២គីឡូម៉ែត្រ ឋិតនៅខាងលិច សាលាស្រុក ។ នៅទីនេះយើងជួបគណៈកម្មការវត្តចៅអធិការវត្តចំការខ្នុរ និងសាក្សីផង ។

សាក្សីទី១ឈ្មោះ **ចិន សារ៉ែ** អាយុ៦៥ឆ្នាំ ភេទប្រុស សក់ស្កូវ កំពស់ ១,៦៧ម៉ែត្រ មាឌខ្ពស់ ដំបង សម្បុរ ស ។ សម័យ **ប៉ុល ពត** ជំលៀសចេញ ក្រោយឆ្នាំ១៩៧៩ មកនៅភូមិអូរអំបិល ឃុំអូរអំបិល គាត់បានដឹងពុំនិងបានឃើញពេលចូលមកតំបន់នោះ និងចូលរួមគាស់ឆ្អឹងយកមាសឆ្នាំ១៩៨៣-៨៤ ។

អដ្ឋិធាតុគាស់ យកទៅតំកល់ទុកនៅ ***សារៈមន្ទីរវត្តសុភមង្គល*** **E 102º 57' 4308" N 13º 35' 1272"** (ភូមិអូរបិល ឃុំអូរបិល ស្រុកស៊ីសុផុន) សំរាប់ធ្វើបុណ្យរៀងរាល់ឆ្នាំ អដ្ឋិធាតុនៅសល់ខ្លះ ចោរលួចអស់ខ្លះៗហើយ មុនឆ្នាំ៩៧ នេះ ។

តាមរយៈសាក្សីទី១នេះ គាត់បាននាំយើងទៅពិនិត្យរណ្ដៅកន្លែងពិឃាតផ្ទាល់ភ្នែក យើងបានថតទីតាំងរណ្ដៅ និង សាក្សីចង្អុលបង្ហាញ និង ប៉ាន់ស្មានដឹងថា បរិវេណដី ទំហំ ១ហិកតា បួនជ្រុង ចន្លោះភ្នំកូនខ្លា ភ្នំស្វាយ និងភ្នំអញ្ចាំង រណ្ដៅអមជើងភ្នំ ក្នុងចំការខ្នុរ បច្ចុប្បន្នចំការដំណាំអ្នកស្រុក ។

ចំនួនរណ្ដៅលប់អស់ជាច្រើន នៅខ្លះៗ យើងបានសួរអំពីពេលគាត់កំពុងគាស់ និងឃើញគេគាស់ ជាទទឹង៥ម៉ែត្រ បណ្ដោយ ៦ម៉ែត្រ ទៅ ១០ម៉ែត្រ ជំរៅ ១,៥០ ទៅ ២ម៉ែត្រ សាកសពពេញទាំងអស់ រណ្ដៅអាចស្មាន ជាប្រហែល ១០០ ទាំងតូចធំ និងមិនអាចរាប់អស់ទេ ។

សាក្សីទី២ : លោកតា **សាន មាន** អាយុ ៦៨ឆ្នាំ អាចារ្យវត្តសុភមង្គល គាត់ជាសាក្សីដ៏សំខាន់ មាឌមាំ កំពស់ ១,៦០ម៉ែត្រ សក់ស្កូវ សម្បុរ ស ឆ្នាំ១៩៧០-១៩៧៥ រស់នៅភូមិខ្នាំង ឃុំកំពង់ ស្វាយ ស្រុកសេរីសោភ័ណ ។ ឆ្នាំ១៩៧៥ ទល់ ១៩៧៩ ឃុំសំរោងស្រុកជ គាត់ជាប្រជាជនធម្មតា ។

គាត់បានអោយយើងដឹងថា មណ្ឌលឧក្រិដ្ឋកម្ម នេះជាកន្លែងសម្លាប់ដ៏ធំ មានពីរកន្លែង ទីនោះគឺ :

+ ទីI : ចំការខ្នុរ

+ ទីII : ភ្នំកូនខ្លា ចន្លោះភ្នំអញ្ចាំង

លោកតានេះ ប្រធានអាចារ្យទូទាំងស្រុក ហើយមកនៅស្រុកកំណើតមុនគេ ព្រមទាំងយកប្រាក់វត្តជួល គេជីកគាស់យកឆ្អឹងសាកសព១បាវ ២០បាត នៅឆ្នាំ១៩៧៩ រហូតឆ្នាំ១៩៨៣ ប៉ុន្តែជីកមិនអស់ទេ ច្រើនណាស់ ។

គាត់បន្ថែមប្រាប់យើងថា ប្រភេទជនរងគ្រោះស្លាប់ទីនោះ គេដឹកទាំងឡានៗ មាន២០ឡាន ១០ឡានម្ដងៗ និងយកពីគ្រប់ទិសទី គេបោកបញ្ឆោតថា បញ្ជូនទៅថៃ ប៉ុន្តែ ធាតុពិត សម្លាប់ទីនេះទាំងអស់។ ជនរងគ្រោះស្លាប់ទីនោះចំរុះ ទាហ៊ាន មន្ត្រីរដ្ឋការ ស៊ីវិល សិស្ស និស្សិត គ្រូបង្រៀន សាស្ត្រាចារ្យ ប៉ូលីស

ប៉េអ៊ីម ។ល។ មានខ្មែរ ចិន យួន ។ សម្លាប់ផ្តាច់តែម្តង អ្នកស្លាប់ច្រើន មានក្មេង ចាស់ ប្រុស ស្រី ទាំង គ្រួសារៗ តែម្តង ។ យើងសំភាសន៍លំអិត ក្នុងកាសែ្សតរួចហើយ ទុកជាឯកសារគួបផ្សំ ។

សាក្សីទី៣ ៖ គឺ លោកអាចារ្យ **ឃួន សាល** គាត់អតីត ៖ ជាគ្រូសូត្រធ្មំា វត្តបន្ទាយ រាង **ប៉ុល ពត** ចាប់ដាក់គុកនៅសន្តិសុខវត្តចំការខ្នុរផ្ទាល់ គាត់ឮឃើញផ្ទាល់នឹងភ្នែក មានពេលមួយ រថយន្តដឹកមក២០ឡានធំៗ ពួកវាវាប់ឈ្មោះម្តង២០.០០០ម៉ឺននាក់ រួចចងដៃដាក់ខ្សោះអោយឡើងឡាន ដឹកទៅនៅម៉ោង៧យប់ រថយន្តមកវិញម៉ោង៩យប់ សល់តែខោអាវ និងខ្សោះ ឯមនុស្សបាត់អស់ នេះគាត់ថា គេដឹកទៅថៃ តែជាគុពិត មិនមែនទេ សម្លាប់តែម្តង ។

ដូច្នេះទីតាំងសម្លាប់គុកសន្តិសុខ ចំការខ្នុរ វត្តចំការខ្នុរ អាចសន្និដ្ឋានថា ជាង ២០.០០០នាក់ (ជាង ពីរម៉ឺននាក់) ទៅ ២៥.០០០នាក់ ។

* នៅម៉ោង១១៖៤៥ យើងទៅពិនិត្យអដ្ឋិធាតុតំកល់ទុកនៅសារៈមន្ទីរ ក្នុងវត្តសុភមង្គល E102º 57' 4308" N 13º 35' 1272" តាមផ្លូវជាតិលេខ៥ ៖ យើងបានថតទុកឯកសារជាភស្តុតាង ការទុកដាក់ សមរម្យល្អ ប៉ុន្តែគួរអោយសោកស្តាយ រយៈកន្លងមក មុនឆ្នាំ១៩៩៧ មានចោរអាររបង លួច អដ្ឋិធាតុបាត់អស់ មួយចំនួនទៅហើយ លោកអាចារ្យដែលបានគ្រប់គ្រង គាត់ថា ការពារមិនឈ្នះ គេលួច ពេលយប់ៗ ។ ប៉ុន្តែក្រោយមក គឺបច្ចុប្បន្ន តាំងពីមានពួកខ្មែរក្រហមផ្តាច់ខ្លួនមក លែងបាត់អដ្ឋិធាតុទៀត ហើយ ។

នៅម៉ោង ១២៖០០ ក្រុមស្រាវជ្រាវយើងបានទៅពិសារបាយនៅខេត្តបន្ទាយមានជ័យវិញ ។

នៅវេលាម៉ោង ១៤៖០០ យើងបានបន្តដំណើរ ទៅកាន់ស្រុកមង្គលបូរី ប៉ុន្តែដោយម៉ោង១សៀល សាលាស្រុកមិនទាន់មានមន្ត្រីចូលធ្វើការ យើងក៏បន្តទៅកាន់មណ្ឌលខក្រិដ្ឋកម្មតែម្តង ។

* **មណ្ឌខក្រិដ្ឋកម្ម** ៖ E 103º 00' 4330" N 13º 25' 5664" ល្អាងភ្នំគួយយំ និងខាងក្រោយ អនុវិទ្យាល័យអូរប្រាសាទ នេះជាកន្លែង សម្លាប់ ជនរងគ្រោះយកពីសន្តិសុខគុក ភូមិធំ ឃុំអូរប្រាសាទ ។ នៅទីនេះជាកន្លែងដ៏ធំមួយដែរ ។ ហើយមណ្ឌលខក្រិដ្ឋកម្មមួយទៀតនៅភូមិភ្នំតូច មានគណៈឃុំ គណៈ ស្រុក របស់បន **ប៉ុល ពត** នៅទីនោះកន្លែងសម្លាប់ ចំការយាយ **ហ៊ីម** ។ យើងបានពិនិត្យផ្ទាល់ទីនេះ ហើយបានជួប សាក្សីម្នាក់ឈ្មោះ លោកតា **នុត ខិញ** គាត់បានបំភ្លឺអោយយើងបានដឹងថា ៖ គាត់អាយុ ៦១ឆ្នាំ កំពស់ ១,៦៦ម៉ែត្រ សម្បុរ ខ្មៅ សក់ខ្មៅ មាឌធំដំបង គាត់មានស្រុកកំណើតនៅទីនោះតែម្តង ។

- គាត់ជាអ្នកជាប់គុកផ្ទាល់ ដោយគាត់មានកំហុសបង្កាប់កូនក្មេងសម្លាប់ជ្រូកយកសាច់ហូប គាត់ មានភូមិកំណើត ភូមិភ្នំតូច ឃុំភ្នំតូចនេះ ជាប្រធានរោងបាយ **ប៉ុល ពត** សម័យនោះផង ។ គាត់ប្រាប់

យើងបន្ថែមថា អ្នកជាប់ទោសជាមួយគាត់ មានទោសធ្ងន់ ដាក់ខ្នោះមិនបណ្តើរអោយធ្វើការទេ ដាក់ទាំងយប់ថ្ងៃ ឯប្រភេទទោសស្រាលបណ្តើរអោយធ្វើការ តែក្រោយៗ សម្លាប់ទាំងអស់ នៅឆ្នាំ១៩៧៨ មុនឆ្នាំ ១៩៧៩ នៅគុកសន្តិសុខភូមិធំ ខាងក្រោយអនុវិទ្យាល័យអូរប្រាសាទ ពួកជាប់ទោស ដាក់ខ្នោះជើង ។ ចំពោះកន្លែងសំលាប់ នៅល្អាងភ្នំ ភូមិធំ ភ្នំធំ និងមួយកន្លែងទៀត ជើងភ្នំធំ ក្រោយអនុវិទ្យាល័យអូរប្រាសាទ ។ ហើយប្រភេទជនរងគ្រោះយកពីគ្រប់កន្លែង មកដាក់គុក ភូមិធំនេះ ហើយយកទៅសម្លាប់នៅល្អាងភ្នំធំ និងជើងភ្នំធំ ស្រុកមង្គលបូរីនេះ ។ គាត់បានបំភ្លឺប្រាប់យើងថាគណៈឃុំ **តាញឹម** និងគណៈស្រុកឈ្មោះ **តាឬ** គាត់នោះកាចសាហាវណាស់ ។

* សាក្សីទី២ ឈ្មោះ **អុល ខុស** អាយុ ៤០ឆ្នាំ ភេទ ប្រុស ធ្លាប់រស់នៅភូមិធំ ឃុំអូរប្រាសាទ ស្រុកមង្គលបូរី ហើយជំនាន់ **ប៉ុលពត** កម្មករវាយថ្ម ធ្លាប់ជាប់គុកពីឆ្នាំ១៩៧៨ ទល់ ១៩៧៩ ។ បច្ចុប្បន្ន នៅភូមិភ្នំធំ ឃុំអូរប្រាសាទ ស្រុកមង្គលបូរី ។

សាក្សីរូបនេះបានប្រាប់យើងថា ពួក **ប៉ុល ពត** បានចាប់កម្មករវាយថ្មចំនួន ១០០នាក់ ក្នុងនោះមានរូបគាត់ផង ហើយក្នុង១០០នាក់ យកទៅសម្លាប់ ល្អាងភ្នំធំនេះ មានរស់តិចណាស់ ។ ពេលរស់នោះគឺបែកឆ្នាំ១៩៧៩ ឯអ្នកមកចាប់សម្លាប់ កម្មករ ពួកនិរតី ។ កន្លែងសម្លាប់ល្អាងភ្នំធំ ឬ ល្អាងគួយឃំ បច្ចុប្បន្នខាងក្រោយផ្ទះសាក្សីរូបនេះតែម្តង ។

ចំពោះល្អាងភ្នំគួយឃំនេះជំរៅ ១០ម៉ែត្រ និងមួយកន្លែងទៀតខាងក្រោយអនុវិទ្យាល័យអូរប្រា សាទ ទីនេះជើងភ្នំភូមិធំ គាត់បានប្រាប់យើងថា គេដឹកឡានម្តង ១ឡាន ២ឡាន យូរៗដឹកមកម្តង សម្លាប់ទាំងអស់តែម្តង ។

* សាក្សីទី៣ ម្នាក់ទៀត **អ៊ុី ភន** អាយុ ៥០ឆ្នាំ គាត់បាននិយាយប្រាប់យើងដូចសាក្សីទី២ និងបច្ចុប្បន្ននេះគាត់រស់នៅភូមិភ្នំធំនោះ ដូចសាក្សីទី២ នេះដែរ ។ គាត់បន្ថែមថា គេដឹកយកមកសម្លាប់ពេលយប់ ។

ជនរងគ្រោះស្លាប់ទីនេះប្រហែល ពី ១០០នាក់ ទៅ ២០០នាក់ ។

* **នៅម៉ោង ១៥:០០ យើងទៅពិនិត្យមណ្ឌលឧក្រិដ្ឋកម្ម ភូមិភ្នំតូច ចំការ យាយ ហ៊ឹម**

E 103º 01' 0109" N 13º 24' 4006" បានជួបសាក្សីឈ្មោះ **គុល ភន** អាយុ ៥៣ឆ្នាំ សម័យ **ប៉ុល ពត** រស់នៅភូមិភ្នំតូចខាងជើង ឃុំភ្នំតូច បច្ចុប្បន្នគាត់នៅភូមិដ ឃុំដ ស្រុកមង្គលបូរី ។ គាត់មកទីនេះនៅឆ្នាំ១៩៧៩ ឃើញផ្ទាល់ភ្នែក ទីតាំងសម្លាប់នេះមានរណ្តៅជាប្រឡាយ វាយសម្លាប់ ប្រហែល១០០នាក់ នៅទីនេះ ។ ទីនេះបច្ចុប្បន្ន នៅខាងក្រោយផ្ទះ **យាយហ៊ឹម** ។

នៅម៉ោង ១៦:៣០ យើងបន្តដំណើរទៅកាន់

***មណ្ឌលឧក្រិដ្ឋកម្ម វត្តបន្ទាយចាង :**

**+ ទីនោះសន្តិសុខ និងគុក កន្លែងសម្លាប់** : E 103º 00' 5054" N 13º 30' 4094"

នៅមណ្ឌលឧក្រិដ្ឋកម្ម នេះ យើងបានជួបសាក្សីឈ្មោះលោកតាអាចារ្យ **ឃួន សាយ** អាយុ ៥៨ឆ្នាំ គាត់មានកំពស់ ១,៦៦ម៉ែត្រ មាឌធំ សម្បុរស ជាអ្នកធ្លាប់ជាប់គុកជំនាន់ **ប៉ុល ពត** បច្ចុប្បន្ន នៅភូមិធំ ឃុំបន្ទាយចាង ស្រុកមង្គលបូរី ។ គាត់ជាប់គុកឆ្នាំ១៩៧៦ រហូតឆ្នាំ១៩៧៧ នៅគុកចំការខ្នុរ វត្តចំការខ្នុរ ក្នុងស្រុកសេរីសោភ័ណ ។ សាក្សីម្នាក់ទៀត ឈ្មោះ **ស្រីប ថ្លាង** អាយុ ៦០ឆ្នាំ រស់នៅភូមិធំ ឃុំ និងស្រុក ដូចសាក្សីទី១ ដែរ ។

យើងបានដឹងតាមរយៈសាក្សីទាំងពីរនាក់ នោះថា នៅមណ្ឌលឧក្រិដ្ឋកម្មនេះ ពួក **ប៉ុល ពត** យកព្រះវិហារធ្វើគុក មន្ទីរសន្តិសុខ យកកុដិលោកសង្ឃ វត្តបន្ទាយចាងនេះ ឯកន្លែងសួរចម្លើយ និងសម្លាប់ នៅមុខវត្តបន្ទាយចាងនេះតែម្តង ។

សាក្សីបាននាំយើងទៅពិនិត្យរណ្តៅមុខវត្ត ទីនេះរលប់ស្ទើរអស់ទៅហើយ គាត់បានប្រាប់យើងថា រណ្តៅច្រើនណាស់ ឃ្លាតពីមួយទៅមួយ តែ១ម៉ែត្រទេ អាចប៉ាន់ស្មានថា ពី ១០០រណ្តៅ ទៅ ២០០រណ្តៅ មាន ពេញទំហំដី ១ហិកតា បួនជ្រុង និង បណ្តោយប្រឡាយយោធា ចំនួន ៥០០ម៉ែត្រ ទៅ ១០០០ម៉ែត្រ សុទ្ធតែរណ្តៅដែរ ។ គាត់បានស្មានពេលនោះថា ១រណ្តៅមាន២០ ទៅ២៥នាក់ អាចមាន៣០នាក់ក៏មាន ។ ចំពោះជនរងគ្រោះនៅទីនោះនៅឆ្នាំ១៩៧៩ ពួកយៀកណាម មកជីកយកខ្មោះពីព្រះវិហារ មិនដឹងយក ទៅណាទេ ពេលនោះឈាមនៅប្រឡាក់ជញ្ជាំងថ្មីៗ ។ នៅមុខព្រះវិហារមានរណ្តៅដ៏ធំមួយ បំរុងយក ប្រជាជននៅភូមិ-ឃុំនេះមកប្រជុំ ពួកវាបានបោកបញ្ឆោតថា ប្រជុំរួចអោយហូបនុំបញ្ចុក នៅតែ០២ថ្ងៃ ទៀតដល់ថ្ងៃ ប្រជុំ ប៉ុន្តែមិនបានប្រជុំ ប្រទេសជាតិបានរំដោះ ថ្ងៃ៧មករា ឆ្នាំ១៩៧៩ ។

ចំនួនជនរងគ្រោះចំរុះ មន្ត្រីរាជការ ស៊ីវិល និងពួកជាប់ឃុំ ក្នុងវិហារនេះផង ចិន យួន ចំរុះសម្លាប់ ទាំងអស់នៅទីនោះ ប្រហែលពី ៣៥០០នាក់ ទៅ ៥០០០នាក់ គាត់ថាអាចមានច្រើនជាងនេះទៀតផង ។ រូបថតសាក្សី គុកព្រះវិហារ កាស្សែត មានថតទុកជាឯកសារគួបផ្សំផងដែរ ។

***ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ**

នៅថ្ងៃទី៣០.៤.៩៧ វេលាម៉ោង ៧ យើងបានបន្តដំណើរទៅកាន់ស្រុក ព្រះនេត្រព្រះ តាមផ្លូវជាតិលេខ...... ឆ្ពោះទៅខេត្តសៀមរាប ចម្ងាយផ្លូវ ២៣គីឡូម៉ែត្រ ទៅដល់ស្រុក និងទៅដល់មណ្ឌល

ខេត្រិដ្ឋកម្ម ២៧គីឡូម៉ែត្រ យើងបានធ្វើដំណើរដ៏លំបាកបំផុត ផ្លូវនេះពិបាកជាងបណ្តាផ្លូវនានា ទូទាំងខេត្ត ដែលយើងបាន ចុះមុនៗរួចហើយ ។

នៅវេលាម៉ោង ៨:៣០ យើងទៅដល់ យើងបានជួបលោក **ហាប់ សឿន** ប្រធានមន្ទីរស្រុក និងលោក **ថ្លាង ថុង** ប្រធានការិយាល័យវប្បធម៌ វិចិត្រសិល្បៈស្រុកនោះ ។

+ **លក្ខណៈភូមិសាស្ត្រស្រុក** :

- ខាងជើង ទល់ស្រុកថ្មពួក
- ខាងត្បូង មង្គលបូរី
- ខាងលិច ទីរួមខេត្តបន្ទាយមានជ័យ
- ខាងកើត ទល់ស្រុកក្រឡាញ់

ស្រុកនេះឋិតនៅខាងកើតខេត្តបន្ទាយមានជ័យ ឋិតក្នុងតំបន់៥ ភូមិភាគពាយ័ព្យ ។

- ផ្ទៃដីរួម : ៩៨៣.៤០ហិកតា ដីស្រែ ៤៣.៤៣៧ ហិកតា ដីចំការ : ៣.៧៩០ ហិកតា ។ ដីរុករាន : ៣០.៤០០ ហិកតា ។ ភូមិមាន ១០១ ឃុំមាន ៨ឃុំ ចំណុះស្រុកនោះ ។

- ចំនួនប្រជាជន ១២.៣២៤ គ្រួសារ មាន ៦៩.៨៨៣នាក់ ស្រី ៣៥.៤៥៦នាក់ ។ មុខរបរ ប្រជាជនធ្វើស្រែចំការ ។

+ អំពីពត៌មាន ស្តីអំពីមណ្ឌលខេត្រិដ្ឋម្ម ទូទាំងស្រុក ៨ឃុំ មានទាំងអស់ .......... ប៉ុន្តែ យើងទៅ បានតែមួយចំនួនទេ ដោយមណ្ឌលខេត្រិដ្ឋខ្លះនៅឆ្ងាយ សន្តិសុខអាចទៅបាន ហើយគ្មានផ្លូវ និងផ្លូវពិបាក នេះយើងពិនិត្យជាក់ស្តែង ។

+ ស្រុកនោះយើងងាយស្រួល ព្រោះយើងមានឯកសារផ្តល់មក ពីការិយាល័យវប្បធម៌ស្រុក បាន ស្រង់ចាប់ពីឆ្នាំ១៩៨៤មក មានស្ថិតិជនរងគ្រោះទូទាំងឃុំ និង មណ្ឌលខេត្រិដ្ឋកម្មតាមភូមិ ឃុំ ប៉ុន្តែពេល វេលា និងស្ថានភាពបច្ចុប្បន្ន មិនទាន់អំណោយផល អាចធ្វើបានអស់នោះឡើយ ។ តាមឯកសាររបស់ ការិយាល័យវប្បធម៌ស្រុក ឃើញមានជនរងគ្រោះទូទាំង ៨ឃុំ ៧៨.៤៩៦នាក់ មាន ៣៣កន្លែងសម្លាប់ ។

ប៉ុន្តែយើងបានចុះទៅមណ្ឌលខេត្រិដ្ឋកម្ម ៣កន្លែង ស្រុកនេះ គឺវត្តព្រះនេត្រព្រះ កន្លែងសម្លាប់ នៅចំការ **តាលីង** ចំងាយពីវត្ត១០០ម៉ែត្រ ទីនេះមានគណៈឃុំ និងគុកជាប់ផ្លូវចូលវត្ត នៅក្នុងវត្តមាន មន្ទីរពេទ្យ ពួក **ប៉ុល ពត** ។ អ្នកស្លាប់ ២៥៣នាក់ ។

ទី២ : យើងទៅមណ្ឌលខេត្រិដ្ឋកម្ម ព្រៃតារត់ ទីនោះឋិតនៅខាងក្រោយមន្ទីរពេទ្យស្រុក ១០០ ម៉ែត្រ វាយសម្លាប់ចោលទីនោះ ទីនេះគ្មានគុក-សន្តិសុខទេ ។ ចំនួនអ្នកស្លាប់ ៣៨៩០នាក់ ។

ទី៣ ៖ យើងទៅមណ្ឌលខុក្រិដ្ឋកម្ម ភូមិចក្រី ទីនេះឋិតនៅខាងលិច សាលាស្រុក ព្រះនេត្រព្រះ កន្លែងសម្លាប់គ្មានគុក-សន្តិសុខទេ អ្នកស្លាប់ ៣៥៨០នាក់ វាយសម្លាប់ចាក់ចំពុះទុង វាយដុំបដើមដូង ចង និងដើមដូង ។

កន្លែងសម្លាប់ទាំង ០៣នេះ យើងបានទៅដល់ ហើយយើងបានជួបសាក្សីបំភ្លឺ ពត៌មានពិតជាក់ស្តែង និងពិនិត្យថតទីតាំងសម្លាប់ ថតរណ្តៅ សាក្សី សំភាសន៍ សាក្សី រួចមានឯកសារ ។ ប៉ុន្តែរណ្តៅលប់អស់ហើយ ។ នៅទីនេះអដ្ឋិធាតុ យកទៅដាក់លើភ្នំអញ្ចាំង ប៉ុន្តែអន្តរាយបាត់បង់អស់ហើយ ដោយគេលួចបំផ្លាញ ។

* នៅមណ្ឌលខុក្រិដ្ឋកម្ម វត្តព្រះនេត្រព្រះ (ចំការ**តាលីង**) ភូមិប្រាយភ្លើង ឃុំព្រះនេត្រព្រះ E 103º 10' 4707" N 13º 35' 5637" ទីនោះយើង ជួបសាក្សីឈ្មោះ **ធំ សឿន** អាយុ ៤៥ឆ្នាំ ភេទ ប្រុស សក់ខ្មៅ កំពស់ ១,៦០ម៉ែត្រ សម្បុរស ។ គាត់នៅភូមិប្រាយសំរោង ឃុំព្រះនេតព្រះ ជំនាន់ **ប៉ុល ពត** បច្ចុប្បន្ន ភូមិ-ឃុំ-ស្រុក ដដែលនោះ ។

សាក្សីរូបនោះគាត់បានដឹង ឃើញគេសម្លាប់ផ្ទាល់កន្លែងផ្សេង ឯកន្លែងនោះគ្រាន់តែដឹងថា ពេលគាត់មកជីករកមាស គាត់ដឹងថា ១រណ្តៅឃើញជិត ១២០នាក់ ១១០នាក់ មានរណ្តៅ ៦ធំៗ ៤ម៉ែត្រ បួនជ្រុង ជំរៅ២ម៉ែត្រ ។ ដូច្នេះអាចមាន ៦៦០នាក់ ទៅ ៧២០នាក់ ខុសឯកសារ ៤៦៧នាក់ ប៉ុន្តែសាក្សីបានដឹង ។ នៅ ចំការ**តាលីង** ខាងក្រោយសន្តិសុខ គុក ៥០ម៉ែត្រ ទេ ។ នៅទីនោះគណៈឃុំ **ប៉ុល ពត** នៅមានផ្ទះក្បឿង មួយខ្នងសំរាប់ដាក់អ្នកទោស វាយសម្លាប់អស់ដាក់បន្ថែមថ្មី យកមកក្រោយៗទៀត ។ អំពីប្រភេទជនរងគ្រោះស្លាប់នៅទីនេះ ភាគច្រើនមនុស្សចាស់ អាយុ ៤៥ចុះ តាមការឃើញឆ្អឹងលលាដ៍ក្បាល សពជនរងគ្រោះ ហើយជាមន្ត្រីរដ្ឋការ ស៊ីវិល ជំលៀសពីទីក្រុង មានតែប្រុសៗ និងអដ្ឋិធាតុគ្មានសល់ទេ ចាស់ៗឲ្យ ដុតចោលអស់ហើយ ។ ដូច្នេះយើងគ្មានកស្តុតាងឆ្អឹងសល់ទេ ។

នៅវេលាម៉ោង ១០:០០ យើងបានទៅកន្លែង **សម្លាប់ព្រៃតារត់ ភូមិជួប ឃុំជួបវារី E 103º 10' 4334" N 13º 37' 3836" និងភូមិចក្រី ឃុំជួបវារី E 103º 10' 4502" N 13º 37' 2411"** ក្បែរសាលាស្រុក នៅទីនោះ យើងបានសាក្សីឈ្មោះ **ថ្លាង ថុង** អាយុ ៤៩ឆ្នាំ កំពស់ ១,៦៦ម៉ែត្រ គាត់នៅ ភូមិបុស្តិ៍ ឃុំព្រះនេត្រព្រះ ស្រុកព្រះនេត្រព្រះ បច្ចុប្បន្នធ្វើការនៅការិយាល័យវប្បធម៌ស្រុក ។

សាក្សីរូបនេះគាត់គ្រាន់តែដឹងកន្លែងសម្លាប់ ប៉ុន្តែជនរងគ្រោះយកពីណាមក គាត់មិនបានដឹងទេ ឯឆ្អឹងគាត់យកទៅដាក់លើសារៈមន្ទីរភ្នំអញ្ចាំង ប៉ុន្តែខ្វះវិធានការទប់ស្កាត់ ចោរលួចអស់ហើយ តាមពត៌មានខ្លះគាត់ដឹងពីអ្នកដទៃដែរនោះថា នៅទីនោះគ្មានគុក សន្តិសុខ អ្វីទេ គេយកមកសម្លាប់តែម្តង ចំពោះ

ភូមិចក្រី ក៏ដូច្នោះដែរ គាត់ទើបមកធ្វើការក្រោយ ។ យើងសោកស្តាយមិនបានជួបមន្ត្រី **គង់ ប៊ុនធុច** និងសមាជិកស្រុក ចុះហត្ថលេខាលើឯកសារ ឆ្នាំ១៩៨៤ ស្រង់ស្ថិតិជនរងគ្រោះ នៅស្រុកព្រះនេត្រព្រះ នោះឡើយ ។ មន្ត្រីថ្នាក់ស្រុកទៅប្រជុំ ទីក្រុងភ្នំពេញ និងខ្លះទៅខេត្តអស់ ដូច្នេះការស្រាវជ្រាវរកសាក្សី នៅទីនោះមិនទាន់បានល្អទេ ។

ដោយពេលវេលាផង ផ្លូវពិបាកផង និងសន្តិសុខពុំជាសូវល្អ ដូច្នោះយើងមិនអាចនៅយូរស្វែងរក សាក្សី ឬ បន្តការងារទៅកន្លែងធំៗ ដូចជាភ្នំត្រយោង ៤០.០០០នាក់ គុក-សន្តិសុខធំ សម្លាប់ដីខ្លាំងនោះ បានទេ ផ្លូវជាង ២០គីឡូម៉ែត្រ ទៅកាន់ភ្នំនោះ និងពិបាកផង ដូច្នេះយើងសំរេចដកថយ មកខេត្តបាត់ដំបង វិញ នៅល្ងាច ថ្ងៃទី៣០។៤។៩៧ ម៉ោង ១៤:០០ ។

## សេចក្តីសន្និដ្ឋាន

ការចុះខេត្តបន្ទាយមានជ័យលើកនេះ បែបបទទំនាក់ទំនងផ្នែករដ្ឋបាល មន្ត្រីមូលដ្ឋាន ខេត្ត ស្រុក ជារួមបានល្អដែរ ប៉ុន្តែយើងមិនបានជួបមន្ត្រីថ្នាក់ខេត្ត និងថ្នាក់ស្រុកនានា ដែលចុះនោះទេ មូលហេតុអស់ លោកទាំងនោះទៅប្រជុំនៅទីក្រុងភ្នំពេញអស់ ។

ចំពោះមន្ត្រីថ្នាក់ក្រោម មួយចំនួន ដូចជានាយការិយាល័យ មន្ទីរ ការិយាល័យ និងស្នងការប៉ូលីស យើងបានទាក់ទងល្អ និងមួយចំនួនទៀត មិនបានជួបដោយគេមិននៅ ដូច្នេះការសំរេចចុះរំលងលទ្ធផល មិនសូវល្អដែរទេ យើងខ្វះឯកសារ និងការបំភ្លឺពត៌មានជាក់ស្តែងរបស់មន្ត្រីបច្ចេកទេសផ្ទាល់ ។ ឧទាហរណ៍ មន្ត្រីវប្បធម៌ស្រុក-ខេត្ត ។

ដូច្នេះក្នុងស្ថានភាព ខេត្ត ក៏ដូចប្រទេសជាតិ ក្នុងកាលៈទេសៈនេះ ហើយជាពិសេស មូលដ្ឋានជន បទ ឥឡូវនេះត្រូវទាមទារ ស្ទាបស្ទង់ ដើរមួយជំហ៊ានត្រូវគិតជងដែរ ។ មានកន្លែងខ្លះមិនអាចទៅបាន សោះឡើយ ។

អំពីលទ្ធផល ក្នុងស្រុកទាំង៣ គឺស្រុកសេរីសោភ័ណ ស្រុកមង្គលបូរី និងស្រុកព្រះនេត្រព្រះ យើងបានចុះ ៩ទីតាំង គឺ :

+ ស្រុកសេរីសោភ័ណ :

- ចំការខ្មុរ វត្តចំការខ្មុរ
- កន្លែងសម្លាប់ ភ្នំកូនខ្លា និង ចំការខ្មុរ

- សារៈមន្ទីរ វត្តសុភមង្គល

+ ស្រុកមង្គលបូរី ៖

- មណ្ឌលឧក្រិដ្ឋកម្ម ភូមិភ្នំធំ គុក-សន្តិសុខ

- កន្លែងសម្លាប់ ល្អាងភ្នំធំ (ល្អាងគួយយំ)

- ខាងក្រោយអនុវិទ្យាល័យអូរប្រាសាទ

- មណ្ឌលឧក្រិដ្ឋកម្ម ភូមិភ្នំតូច ឃុំភ្នំតូច

- កន្លែងសម្លាប់ ចំការ **យាយហ៊ឹម**

+ ស្រុកព្រះនេត្រព្រះ ៖

- មណ្ឌលឧក្រិដ្ឋកម្ម វត្តព្រះនេត្រព្រះ គុក-សន្តិសុខ

- ចំការ **តាលីង**

- កន្លែងសម្លាប់ ក្នុងចំការ **តាលីង** ក្បែរវត្តចម្ងាយ ១០០ម៉ែត្រ ទៅ ២០០ម៉ែត្រ ។

- ព្រៃតារត់ ខាងក្រោយមន្ទីរពេទ្យស្រុក

- ភូមិចក្រី ខាងមុខសាលាស្រុក ។

ផ្អែកលើលទ្ធផលនេះ យើងប្រឹងប្រែងរត់តាមពេលវេលា ដូច្នេះលទ្ធផលច្រើន និងបានគ្រប់ជ្រុងជ្រោយនោះមិនបានដូចបំណងនោះទេ វាអាចខុះមុខក្រោយដែរ ឧទាហរណ៍ ការទាក់ទង យើងខុះខាងដូចជាស្រុកខ្លះយើងមិនបានជួបមន្ត្រីដឹកនាំស្រុក និងពិសេស មន្ត្រីវប្បធម៌ ដូច្នេះពត៌មានប្រយោល យើងខ្វះឯកសារ ។

ប៉ុន្តែលទ្ធផលល្អ យើងទទួលបានឯកសារពីមន្ទីរវប្បធម៌លក់ និងស្រុកព្រះនេត្រព្រះ យើងជឿជាក់ថា បទពិសោធន៍ថ្ងៃខាងមុខ និងបានល្អថែមទៀត លើការទំនាក់ទំនងមន្ត្រីមូលដ្ឋាន មិនអាចកាត់ផ្តាច់ បានយើងមិនត្រូវរត់រកបរិមាណពេកនោះទេ ត្រូវគិតអោយបាននូវគុណភាព ម៉ត់ចត់បន្តិចដាងនេះទៀត ទើបល្អ ។

## យោបល់

បើសិនជាយើងមានឧបករណ៍ថតខ្សែភាពយន្តវីដេអូ ថតជាខ្សែវីដេអូឯកសារស្តីអំពីអំពើឧក្រិដ្ឋ កម្មគួបផ្សំមធ្យោបាយគ្រប់គ្រាន់ យើងពិតជាមានឯកសារច្បាស់លាស់ជាង យើងស្តាយពេលវេលាដ៏លំបាកនេះ កន្លងផុត ដោយខ្វះឧបករណ៍ថតឯកសារទាំងនេះ ។

ធ្វើនៅខេត្តបាត់ដំបង,ថ្ងៃទី ០៧ ១៥ ១៩៧

អ្នកចុះស្រាវជ្រាវផ្ទាល់

**ស៊ិន ឃិន**